# រឿង ពពក និង កូនផ្កា



គូរដោយ គីម សុគន្ធ

# បុព្វកថា

******

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារនេះ បានរៀបរៀងឡើងក្នុងគោលបំណង:

- ធ្វើអោយកុមារមានសេចក្តីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- អោយកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជួយដល់ឪពុកម្តាយ រឺលោកគ្រូ អ្នកគ្រូ ក្នុងការនិទានរឿងសំរាប់កុមារ

យើងខ្ញុំរង់ចាំទទួលនូវការផ្តល់មតិកែលំអពីមិត្តអ្នកអានទាំងអស់ដោយសេចក្តីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ

# រឿង ពពក និង កូនផ្កា



និពន្ធដោយ កែវ ណារុំ

វិចិត្ររូបភាពដោយ គីម សុគន្ធ

អ្នកបោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)



នៅមុខផ្ទះមួយ    មានដើមផ្កាក្ដាំងងាមួយដើមធំកំពុងបញ្ចេញផ្កាយ៉ាងច្រើនក្រអូបឈ្ងុយឈ្ងប់ ។





លោកតាម្ចាស់ផ្ទះ  បានកាត់មែកក្ដាំងងាបំបែកផ្សាំដាក់ក្នុងកូនជាលជាច្រើន ដើម្បីទុកចែកចាយញាតិមិត្ត ។ លោកតាថែដាក់ជី និងស្រោចទឹកជារៀងរាល់ថ្ងៃ ។



ថ្ងៃមួយលោកតាបានដួល ព្រោះជំពប់ជើងនឹងដុំថ្ម ។ អ្នកជិតខាងក៏ស្ទុះមកគ្រាហ៍លោកតា យកទៅព្យាបាលនៅមន្ទីរពេទ្យ ។







កូនផ្កាក្នុងជាល គ្មានអ្នកស្រោចទឹក ។ វាមិនអាចទប់ទល់ចំពោះភាពខ្សោះទឹកបាន  ក៏ស្រែកហៅ ពពកនៅលើមេឃអោយបង្អុរភ្លៀងស្រោចលើខ្លួនវាផង ។





ពពកឆ្លើយថា «ពួកយើងរវល់ណាស់ ព្រោះថ្ងៃនេះយើងត្រូវទៅស្រោចរុក្ខជាតិ ឯផ្ទះលោកម្ចាស់»។



ដើមក្តាំងងាធំក៏បានជួយអង្វរដែរថា «រុក្ខជាតិធំៗ ដូចពួកខ្ញុំមានឫសជ្រៅអាចទ្រាំបានយូរថ្ងៃ ។ សូមបងពពកជួយកូនផ្កាតូចៗនេះសិនទៅ» ។





ពពកឆ្លើយថា « មិនបានទេ
ខ្ញុំត្រូវតែទៅ ចាំថ្ងៃខានស្អែក
ខ្ញុំនឹងត្រលប់មកបង្អុរភ្លៀង
ស្រោចអោយពួកអ្នក » ។

ក្រោយមក ពពកបាន ត្រលប់មកតាមពាក្យសន្យា មែន តែអ្វីៗ បានហួសអស់ហើយ ។ កូនផ្កាដែលត្រូវ សង្គ្រោះជាបន្ទាន់នោះ បាន ស្វិតងាប់អស់រលីង ។





ពពកនឹកស្តាយក្រោយ
ព្រោះតែចង់ផ្គាប់ផ្គុនលោក
ម្ចាស់ពេក មិនបានគិតអោយ
បានច្បាស់ពីជីវិតរបស់កូន
ផ្កាតូចៗ ។



ឃើញដូច្នោះ ដើមក្តាំងងាដ៏ធំនោះ មិននិយាយវែងឆ្ងាយទេ គ្រាន់តែពោលយ៉ាងខ្លីថា « ហ៊ី! ពពកអើយ ប្រសិនបើអ្នកគិតអោយច្បាស់លាស់ ម្ល៉េះសមកូនផ្កាមិនស្លាប់ទេ » ។

៙ចប់៚



# រឿង ពពក និង កូនផ្កា

និពន្ធដោយ អ្នកស្រី កែវ ណារុំ
គូររូបដោយ លោក គឹម សុគន្ធ
រក្សាសិទ្ធិដោយ អង្គការសន្តិស្មគ្រចិត្ត(SVA)
បោះពុម្ពឆ្នាំ២០០២

